May 17, 2019

# អាល្លឺម៉ង់ផ្តល់ជំនួយជិត៦៦លានដុល្លារដល់កម្ពុជាដោយភ្ជាប់លក្ខខណ្ឌសិទ្ធិមនុស្ស




លោក Norbert Barthle តំណាងគណៈប្រតិភូអាល្លឺម៉ង់ និងលោកឈៀង យ៉ាណារ៉ា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការអភិវឌ្ឍរវាងប្រទេសទាំងពីរនៅទីក្រុងប៊ែឡាំង ប្រទេសអាល្លឺម៉ង់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩។ (រូបថតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)

**កាន់ វិច្ឆិកា | VOA Khmer, 16 ឧសភា 2019**

*ក្រោយរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងគណៈប្រតិភូកម្ពុជាបានបញ្ចប់ការចរចាជាមួយរដ្ឋាភិបាលទីក្រុងប៊ែឡាំង ប្រទេសអាល្លឺម៉ង់បានសម្រេចផ្តល់ជំនួយជិត ៦៦ លានដុល្លារអាមេរិកដោយមានលក្ខខណ្ឌសិទ្ធិមនុស្សដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។*

*ភ្នំពេញ — រដ្ឋាភិបាលអាល្លឺម៉ង់សម្រេចផ្តល់ជំនួយដល់កម្ពុជាជិត ៦៦ លានដុល្លារអាមេរិកដើម្បីចូលរួមលុបបំបាត់ភាពក្រីក្រ ដោយភ្ជាប់លក្ខខណ្ឌឲ្យប្រទេសកម្ពុជាគោរពសិទ្ធិមនុស្សឲ្យបានពេញលេញ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតអាល្លឺម៉ង់ប្រចាំកម្ពុជា ដែល VOA ទទួលបាន។*

*សេចក្តីប្រកាសព័ត៌មាននោះបញ្ជាក់ថា រដ្ឋាភិបាលអាល្លឺម៉ង់នឹងផ្តល់ជំនួយដែលជាប្រាក់កម្ចី និងជំនួយឥតសំណងចំនួន ៥៨,៦ លានអឺរ៉ូ ឬស្មើនឹងប្រមាណជាជិត ៦៦ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៩ និង ២០២០ ដើម្បីឲ្យកម្ពុជាកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ គណនេយ្យភាពសង្គម ការកសាងសមត្ថភាពរបស់មណ្ឌលសុខភាពសាធារណៈ និងកិច្ចអភិវឌ្ឍន៍ជនបទ។ គម្រោងទាំងនេះជាគោលដៅកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។*

សេចក្តីប្រកាសព័ត៌មានដដែលគួសបញ្ជាក់ថា៖

«ការគោរពសិទ្ធិមនុស្ស សិទ្ធិក្នុងសង្គម និងសិទ្ធិចូលរួមនយោបាយគឺជាមូលដ្ឋានគ្រឹះរបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់»។

លោក Norbert Barthle សមាជិកសភាអាល្លឺម៉ង់ និងជារដ្ឋលេខាធិការក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍មានប្រសាសន៍ក្នុងសេចក្តីប្រកាសព័ត៌មាននោះថា៖ «ការលុបបំបាត់ភាពក្រីក្រ...គឺជាគោលដៅរបស់ពួកយើង»។

ដោយមិនប្រើពាក្យចំៗពេក លោកសង្កត់ធ្ងន់លើការភ្ជាប់លក្ខខណ្ឌថា៖

«ប្រសិនបើលំហនយោបាយ និងសង្គមពិតជាត្រូវបានបើកចំហ កម្ពុជានឹងអាចគេចផុតពីការបាត់បង់នូវក្របខណ្ឌគាំពារពិសេសផ្នែកពាណិជ្ជកម្ម (EBA Preferences)។ ច្បាប់ជាតិ និងការអនុវត្តជាក់ស្តែងត្រូវតែស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ដូចជាសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពខាងការជួបជុំ និងប្រមូលផ្តុំ។ ខ្ញុំជឿជាក់ថា វាមិនពិបាកនឹងសម្រេចទេ»។

ក្នុងចំណោមទឹកប្រាក់ចំនួនជិត ៦៦ លានដុល្លារអាមេរិកនោះ មានឥណទានជាកម្ចីសម្រាប់គម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ៣០ លានអឺរ៉ូ ឬស្មើនឹងជិត ៣៤ លានដុល្លារ និង ២៨,៦ លានអឺរ៉ូ ឬស្មើនឹងជាង ៣២ លានដុល្លារ ជាជំនួយឥតសំណងសម្រាប់អភិវឌ្ឍន៍វិស័យអាហារូបត្ថម្ភ និងប្រព័ន្ធគណនេយ្យភាពសង្គម សុខភាពសាធារណៈ និងអភិវឌ្ឍន៍ជនបទ។

ការសម្រេចផ្តល់ជំនួយពីរដ្ឋាភិបាលអាល្លឺម៉ង់ធ្វើឡើង ខណៈដែលគណៈប្រតិភូកម្ពុជាបានបញ្ចប់ទស្សនកិច្ចរយៈពេលបីថ្ងៃក្នុងប្រទេសអាល្លឺម៉ង់ នៅថ្ងៃព្រហស្បតិ៍នេះ។ គណៈប្រតិភូដែលដឹកនាំដោយលោក ឈៀង យ៉ាណារ៉ា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានចរចាជាមួយប្រទេសអាល្លឺម៉ង់អំពីជំនួយខាងលើ។

VOA មិនទាន់អាចទាក់ទងសុំការអត្ថាធិប្បាយពីលោក ឈាង យ៉ាណារ៉ា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានទេ។

យ៉ាងណាក្តី លើទំព័រហ្វេសប៊ុករបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គ្រាន់តែបានផ្សព្វផ្សាយអំពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូកម្ពុជាដោយបញ្ជាក់ថា៖

«ការចរចានោះផ្តោតសំខាន់លើការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍របស់អាល្លឺម៉ង់ដល់កម្ពុជា សម្រាប់ឆ្នាំ ២០១៩-២០២០ »ប៉ុណ្ណោះ។

ការផ្តល់ឥណទានជាកម្ចីចំនួនជាង ៣០ លានដុល្លារអាមេរិកដោយប្រទេសអាល្លឺម៉ង់នៅពេលនេះ គឺជាផ្នែកមួយស្ថិតក្នុងគម្រោងជំនួយផ្នែកកម្ចីសរុបចំនួន ៨០ លានអឺរ៉ូ ដែលផ្តល់ដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងសហភាពអឺរ៉ុប។

កាលពីចុងខែកុម្ភៈឆ្នាំ ២០១៩ នេះ រដ្ឋាភិបាលអាល្លឺម៉ង់ផ្តល់ថវិកាជិត ៦ លានដុល្លារអាមេរិកដល់កម្ពុជាដើម្បីពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលនៅកម្ពុជា ព្រមទាំងរំឭកឲ្យរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ខិតខំស្តារលទ្ធិប្រជាធិបតេយ្យដើម្បីរក្សាប្រព័ន្ធអនុគ្រោះពន្ធលើការនាំចេញទំនិញកម្ពុជាទៅអឺរ៉ុប។

ការរំឭកជារឿយៗរបស់អាល្លឺម៉ង់ឲ្យកម្ពុជារក្សាទុកប្រព័ន្ធអនុគ្រោះពន្ធ EBA ធ្វើឡើងខណៈដែលសហភាពអឺរ៉ុបកំពុងដំណើរការនីតិវិធីដកប្រព័ន្ធអនុគ្រោះពន្ធ ដែលផ្តល់ផលចំណេញដល់កម្ពុជាប្រមាណជាជិត ៧០០ លានដុល្លារក្នុងមួយឆ្នាំៗនេះ ដោយសារការរំលោភសិទ្ធិមនុស្ស។

យ៉ាងណាក្តី ក្រុមមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជាក៏បានអះអាងថា កម្ពុជាបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធ EBA បើទោះបីជាអ្នកជំនាញផ្នែកសេដ្ឋកិច្ចអះអាងថា កម្ពុជានឹងរងវិបត្តិ ប្រសិនបើបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធដ៏សំខាន់មួយនេះ៕